#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី៩៖
# ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

Draft

# ជំពូកទី៩: ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

## ៩.១ សេចក្តីផ្តើម

ការវិភាគតម្លៃសេដ្ឋកិច្ច និងបរិស្ថាន គឺជាផ្នែកមួយដ៏សំខាន់ក្នុងការកំណត់ឱ្យឃើញ ថាតើគម្រោងវិនិយោគ អាចប្រព្រឹត្តទៅបានដោយរលូនឬយ៉ាងណា ដោយផ្អែកលើទំហំនៃផលប៉ះពាល់លើបរិស្ថាន និងសង្គម ដែលអាចកើតចេញពីសកម្មភាពរបស់គម្រោង។ ការពណ៌នាអំពីលក្ខណៈសេដ្ឋកិច្ចរបស់ក្រុមហ៊ុន និងហេតុប៉ះពាល់នានាលើបរិស្ថាន-សង្គម ត្រូវបានប៉ាន់ស្មានគិតជាតម្លៃសេដ្ឋកិច្ច។ ការវិភាគអំពីសេដ្ឋកិច្ច និងតម្លៃបរិស្ថាននៅក្នុងជំពូកនេះ ត្រូវបានអនុវត្តន៍ដោយវិភាគលើអត្ថប្រយោជន៍នៃវត្តមានរបស់គម្រោងវិនិយោគនេះចំពោះសេដ្ឋកិច្ចជាតិ និងសង្គមជាតិ និងការវិភាគលើការខាតបង់នៃធនធានបរិស្ថានមួយចំនួន ដែលអាចបាត់បង់ដោយសារការប្រតិបត្តិគម្រោងនេះ។ ការវិភាគលើអត្ថប្រយោជន៍របស់គម្រោង ត្រូវបានផ្អែកលើលក្ខណៈសេដ្ឋកិច្ច ដែលរដ្ឋាភិបាលកម្ពុជា ក៏ដូចជាសង្គមកម្ពុជាទាំងមូលអាចនឹងទទួលបានដោយប្រយោល ឬដោយផ្ទាល់ពីគម្រោងវិនិយោគនេះផងដែរ។

ផ្នែកសំខាន់ៗចំនួនពីរ ត្រូវបានយកមកវិភាគនៅក្នុងជំពូកនេះ គឺ ១) ការវិភាគផលចំណេញនៃការវិនិយោគគម្រោងនេះចំពោះរដ្ឋាភិបាលតាមរយៈការបង់សួយសារនានា និង ២) ការវិភាគការខូចខាតធនធានបរិស្ថាន-ធនធានធម្មជាតិរបស់កម្ពុជាចំពោះវត្តមានគម្រោងនេះ។

វិធីសាស្ត្រវិភាគជាច្រើន ត្រូវបានប្រើប្រាស់ ដើម្បីវិភាគលើប្រសិទ្ធិភាពសេដ្ឋកិច្ចរបស់គម្រោងវិនិយោគ សម្រាប់ធ្វើការសម្រេចចិត្តថាតើគម្រោងវិនិយោគនោះអាចប្រតិបត្តិបានឬយ៉ាងណា ដោយផ្អែកលើធនធានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងផលប៉ះពាល់លើធនធានបរិស្ថាន និងសង្គម។ វិធីសាស្ត្រទាំងនោះ រួមមានការវិភាគប្រៀបធៀបចំណេញ-ខាត (Cost-Benefit Analysis) ការវិភាគរកតម្លៃនៃអត្រាចំណូល វិនិយោគខាងក្នុង (IRR) និងការវិភាគរករយៈពេលនៃការទទួលបានចំណេញមកវិញ (Payback period)។ ទន្ទឹមនឹងនោះ ការវិភាគកម្រិតបម្រែបម្រួលនៃផលចំណេញ-ខាត (Sensitivity Analysis) ក៏ត្រូវបានប្រើប្រាស់ផងដែរ ដើម្បីធានាថាបម្រែបម្រួលសេដ្ឋកិច្ចទីផ្សារក្នុងតំបន់នឹងមិនជះឥទ្ធិពលពីការអនុវត្តរបស់គម្រោងឡើយ។

ការវិភាគសេដ្ឋកិច្ច និងតម្លៃខូចខាតបរិស្ថានពីសកម្មភាពគម្រោងនេះ ក៏ត្រូវបានធ្វើការវិភាគដោយប្រើប្រាស់វិធីសាស្ត្រ វិភាគប្រៀបធៀបចំណេញ-ខាត ដែលផ្អែកលើផលបូកសរុបនៃការចំណាយបច្ចុប្បន្ន (Total PV Cost) និងផលបូកសរុបនៃចំណូលបច្ចុប្បន្ន (Total PV Benefit) ដោយធ្វើការគណនា ក្នុងរយៈពេល៣០ឆ្នាំ នៃការទទួលបានសម្បទានពីរដ្ឋាភិបាលកម្ពុជា។

## ៩.២ ស្ថានភាពបច្ចុប្បន្ននៃបណ្តាញទូរគមនាគមន៍នៅកម្ពុជា

ប្រព័ន្ធទំនាក់ទំនង និងពត៌មានវិទ្យា (ICT) នៅកម្ពុជាកំពុងតែមានការកើនឡើងនូវតម្រូវការប្រើប្រាស់និងការផ្គត់ផ្គង់ ហើយវាក៏ជាកម្លាំងជំរុញដ៏សំខាន់មួយនៅក្នុងបរិបទនៃការអភិវឌ្ឍន៍។ វាក៏បានចូលរួមរុញច្រានឱ្យមានការកើនឡើងនូវសេដ្ឋកិច្ចកម្ពុជាផងដែរ។ ប្រព័ន្ធទំនាក់ទំនង និងពត៌មានវិទ្យានៅកម្ពុជាបច្ចុប្បន្នបានកំពុងដើរតួរយ៉ាងសំខាន់ក្នុងការរុញច្រានឱ្យមានការកើនឡើងនូវសេដ្ឋកិច្ចទីផ្សារប្រកួតប្រជែងថែមទៀតផង តាមរយៈការទទួលបានពត៌មានអំពីតម្រូវការផលិតផល និងតម្លៃផលិតផលនៅក្នុងទីផ្សារក្នុងតំបន់ និងក្រៅប្រទេស។

របាយការណ៍ទិន្នន័យមូលដ្ឋានឆ្នាំ២០១៥ ចងក្រងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានបង្ហាញថា ហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុន៣ ដែលមានប្រវែងសរុប២៦.៤១១គម ក្នុងនោះមាន ក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា (TC) ប្រវែង១.៦០០គម ក្រុមហ៊ុនវៀតតែល (Viettel) ប្រវែង១៧.២០០គម និងក្រុមហ៊ុនបណ្តាញខ្សែកាប្លិ៍អុបទិចកម្ពុជា (CFOCN) ប្រវែង៧.៦១១គម។ បច្ចុប្បន្ន នៅកម្ពុជាមានក្រុមហ៊ុនទូរស័ព្ទអចល័តចំនួន៩ និងមានក្រុមហ៊ុនទូរស័ព្ទចល័តចំនួន៩ ដែលបានចុះបញ្ជីផ្គត់ផ្គង់សេវាទូរស័ព្ទអចល័ត និងចល័ត។ រីឯ សេវាអ៊ីនធឺណែតចល័ត ត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុនចំនួន៨ និងមានក្រុមហ៊ុនចំនួន២៩បាននឹងកំពុងផ្គត់ផ្គង់សេវាអ៊ីនធឺណែតអចល័តនៅកម្ពុជា។

## ៩.៣ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាលើវិស័យទូរគមនាគមន៍កម្ពុជា

នៅក្នុងអណត្តិទីបួននៃការដឹកនាំរបស់រដ្ឋាភិបាលកម្ពុជា បានបង្ហាញថា វិស័យទូរគមនាគមន៍ នៅកម្ពុជាបានដើរតួរយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងមានការរីកចំរើនខ្លាំងតាមរយៈការពង្រីកដែនគ្របដណ្តប់សេវាកម្មប៉ុស្តិ៍ប្រៃសនីយ៍ ទូរគមនាគមន៍ និងសេវាអ៊ីនធឺណែត។ កត្តានៃការពង្រីកដែនគ្រប់ដណ្តប់សេវាកម្មទូរគមនាគមន៍នេះហើយ បានជំរុញឱ្យមានការកើនឡើងនូវអ្នកប្រើប្រាស់ដ៏ច្រើន។ អាស្រ័យហេតុនេះហើយ នៅក្នុងអណត្តិទីប្រាំនេះ រដ្ឋាភិបាលកម្ពុជានឹងបន្តពង្រីកការអភិវឌ្ឍវិស័យនេះបន្ថែមទៀត ដោយផ្តោតលើការធ្វើទំនើបកម្មវិស័យបច្ចេកទេសពត៌មានវិទ្យា និងទូរគមនាគមន៍ និងដើម្បីធ្វើការធានាឱ្យការផ្តល់នូវសេវាទូរគមនាគមន៍នៅកម្ពុជាទទួលបានការឱ្យតម្លៃខ្ពស់ពីអន្តរជាតិតាមរយៈការផ្តល់សេវាកម្មដ៏មានគុណភាពខ្ពស់បំផុត។ លើសពីនេះទៀត នឹងផ្តល់នូវតម្លៃសេវាកម្ម ដែលមានការប្រកួតប្រជែងទីផ្សារសេរី ដោយមានសេវាគ្រប់ដណ្តប់ទូទាំងប្រទេសសម្រាប់ផ្តល់ជាផលប្រយោជន៍ជូនសាធារណៈជនអាចទទួលបានផលប្រយោជន៍ផ្ទាល់ និងដោយប្រយោលពីការទទួលបានប្រើប្រាស់សេវាទូរគមនាគមន៍នៅកម្ពុជា។ ទិសដៅអតិភាពនៃការអភិវឌ្ឍលើវិស័យទូរគមនាគមន៍នៅកម្ពុជាមានដូចជា៖

Draft

- ការរៀបចំគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាពត៌មានវិទ្យា និងទំនាក់ទំនង (ICT) ដោយមានការគិតគូរពិចារណាលើទិដ្ឋភាពទាំងឡាយនៃសង្គមនិងសេដ្ឋកិច្ច។
- ការលើកកម្ពស់ចំពោះការអនុម័តច្បាប់ស្តីពីការទូរគមនាគមន៍ និងការរៀបចំច្បាប់ពាក់ព័ន្ធនានា។

## ៩.៤ ការសិក្សាអំពីលក្ខណៈសេដ្ឋកិច្ចរបស់គម្រោងវិនិយោគ

គម្រោងខ្សែកាប្លិ៍អុបទិចបង្កប់ក្រោមបាតសមុទ្រនេះ មានការចូលរួមវិនិយោគពីភាគីចំនួនបី គឺភាគីប្រទេសម៉ាឡេស៊ី ប្រទេសថៃឡង់ដ៍ និងប្រទេសកម្ពុជា។ ដោយឡែក ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថានក្នុងគម្រោងនេះ យើងធ្វើការសិក្សាវិភាគតែនៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការសិក្សាអំពីស្ថានភាពហិរញ្ញវត្ថុរបស់ ក្រុមហ៊ុនវិនិយោគនៅកម្ពុជា ការសិក្សានេះនឹងផ្តោតសំខាន់លើ ផែនការចំណាយដែររួមមាន ១).ដំណាក់កាលសាងសង់ (Construction Phase) ២).ដំណាក់កាលប្រតិបត្តិគម្រោង (Operation Phase) និង ៣). តម្លៃទូទាត់សំណងលើការខូចខាតបរិស្ថាន និងសង្គម។ ចំណែកការវិភាគលើចំណូល ឬផលចំណេញដែលក្រុមហ៊ុននឹងទទួលបាន ក៏បានយកមកសិក្សាក្នុងជំពូកនេះផងដែរ។

### ៩.៤.១ ដើមទុនវិនិយោគដែលត្រូវចំណាយក្នុងគម្រោងសាងសង់ខ្សែកាប្លិ៍អុបទិច

#### ក. ការចំណាយក្នុងដំណាក់កាលសាងសង់

ដើមទុនវិនិយោគលើគម្រោងខ្សែកាប្លិ៍អុបទិចក្រោមបាតសមុទ្រឆ្លងកាត់ប្រទេសទាំងបីនេះ គឺមានដើមទុនវិនិយោគប្រមាណ ៤៨លានដុល្លាសហរដ្ឋអាមេរិច ដែលមិនបូកបញ្ចូលការបង់ពន្ធ។ ដូចច្នេះ ខាងភាគីកម្ពុជានឹងទទួលបានទឹកប្រាក់វិនិយោគចំនួន ១៦,៥លានដុល្លាសហរដ្ឋអាមេរិច។ ដោយឡែក ការចំណាយរបស់ក្រុមហ៊ុន TELCOTECH LTD ក្នុងដំណាក់កាលសាងសង់នេះ គឺត្រូវបានប៉ាន់ស្មានស្មើនឹងប្រមាណ **២១,៣លានដុល្លាសហរដ្ឋអាមេរិច** ដែលត្រូវចំណាយទៅលើការងារដូចជា៖ ការងារបង្កប់ខ្សែកាប្លិ៍អុបទិចក្រោមសមុទ្រ ការងារបង្កប់ខ្សែកាប្លិអុបទិចក្រោមដី ការងារសាងសង់ស្ថានីយ៍ចំណតខ្សែកាប្លិ៍និងតំឡើងឧបករណ៍សម្ភារៈ និងការងាររៀបចំប្រព័ន្ធបណ្តាញក្នុងស្រុក។

**តារាង ៩.១ ដើមទុនចំណាយសំខាន់ៗក្នុងដំណាក់កាលដំបូងរបស់គម្រោងវិនិយោគ**

| ចំណាយសំខាន់ៗ | ចំណាយ (គិតដុល្លា) |
|---|---:|
| ការងារបង្កប់ខ្សែកាប្លិអុបទិចក្រោមសមុទ្រ | ១៦.៥០០.០០០ |
| ការងារសាងសង់ស្ថានីយ៍ចំណតខ្សែកាប្លិ៍ | ១.៦០០.០០០ |

| | |
|---|---|
| ការងារធ្វើតេស្តខ្សែកាប្លិ៍ ឧបករណ៍បញ្ជូនបន្ត ឧបករណ៍សំរាប់បែងចែកទិសដៅខ្សែកាប្លិ៍ កិច្ចការប្រជុំ និងការសុំប្រឹក្សាលើឯកទេសផ្សេងៗ | ១.០០០.០០០ |
| ការងាររៀបចំនិងពង្រីកប្រព័ន្ធបណ្តាញខ្សែកាប្លិ៍អុបទិកក្នុងស្រុក | ២.២៥០.០០០ |
| **ចំណាយសរុប** | **២១.៣៥០.០០០** |

### ខ. ការចំណាយក្នុងដំណាក់កាលប្រតិបត្តិគម្រោង

ចំណាយរបស់ **ក្រុមហ៊ុន** TELCOTECH LTD ក្នុងដំណាក់កាលប្រតិបត្តិលើគម្រោងខ្សែកាប្លិ៍អុបទិចក្រោមបាតសមុទ្រ ត្រូវបានប៉ាន់ស្មានស្មើនឹងប្រមាណជាង **៧៦,៥ម៉ឺន ដុល្លារសហរដ្ឋអាមេរិច** ក្នុងមួយឆ្នាំ (តារាង៩.២)។ ការប៉ាន់ប្រមាណ ចំណាយជាក់ស្តែងប្រចាំឆ្នាំរបស់ក្រុមហ៊ុនវិនិយោគ TELCOTECH LTD រួមមាន ១). ចំណាយលើប្រាក់បៀវត្សប្រមាណ១០ម៉ឺនដុល្លា ២). ចំណាយផ្នែករដ្ឋបាលប្រមាណ១០ម៉ឺនដុល្លា ៣). ចំណាយលើសម្ភារៈតំហែទាំប្រមាណជា៣០ម៉ឺនដុល្លា ៤). ចំណាយលើមូលនិធិបរិស្ថាន-សង្គម៤ម៉ឺនដុល្លា និង ៥)ការប៉ាន់ស្មានការចំណាយលើពន្ធនៃប្រាក់ចំណេញប្រមាណជាង២២ម៉ឺនដុល្លា។

តារាង ៩.២៖ ការប៉ាន់ស្មានចំណាយប្រចាំឆ្នាំរបស់គម្រោងក្នុងដំណាក់កាលប្រតិបត្តិ

| **បរិយាយ** | **បរិមាណចំណាយ (គិតជាដុល្លា)** |
|---|---|
| ចំណាយលើប្រាក់បៀវត្ស | ១០០.០០០ |
| ចំណាយផ្នែករដ្ឋបាល | ១០០.០០០ |
| ចំណាយលើសម្ភារៈតំហែទាំ | ៣០០.០០០ |
| ចំណាយមូលនិធិបរិស្ថាន-សង្គម | ៤០.០០០ |
| ចំណាយលើពន្ធនៃប្រាក់ចំណេញ (៥%) | ២២៥.០០០ |
| **សរុបចំណាយថេរ** | **៧៦៥.០០០** |

- **ការចំណាយទៅលើសំណងមូលនិធិ បរិស្ថាន-សង្គម**

ក្រុមហ៊ុនមានកញ្ចប់ថវិការសម្រាប់ចំណាយលើមូលនិធិបរិស្ថាន-សង្គមចំនួន **៤ម៉ឺនដុល្លា** សហរដ្ឋអាមេរិក ហើយមូលនិធិកនេះខាងក្រុមហ៊ុននៅតែបន្តផ្តល់ជារាងរាល់ឆ្នាំទៅតាមការកំណត់របស់ក្រសួងបរិស្ថាន។ ការរួមចំណែកផ្តល់មូលនិធិនេះអាចសបញ្ជាក់ពីការយកចត្តិទុកដាក់ទៅលើបរិស្ថាន និងសង្គមជាតិកម្ពុជាពីសំណាក់ក្រុមហ៊ុនក្នុងការស្តារ និងថែរក្សាធនធានធម្មជាតិក៏ដូចជាផលប៉ះពាល់ទៅលើសង្គម ដែលបណ្តាលមកពីគម្រោងសាងសង់ខ្សែកាប្លិ៍អុបទិច។



Draft

- ការប៉ាន់ប្រមាណចំណាយសួយសារ (ពន្ធអាករ) របស់ក្រុមហ៊ុន

ជាទូទៅការបង់ពន្ធលើប្រាក់ចំណេញ មានការប្រែប្រួលទៅតាមប្រភេទគម្រោង ដោយការចំណាយលើពន្ធប្រាក់ចំណេញចាប់ពី៥% រហូតដល់៣០%នៃប្រាក់ចំណេញរបស់ក្រុមហ៊ុន។ដោយឡែកការប៉ាន់ស្មានការចំណាយ នៃការបង់ពន្ធប្រាក់ចំណេញរបស់ក្រុមហ៊ុនវិនិយោគនេះ ត្រូវបានកំណត់យកត្រឹម៥% ដោយសារប្រភេទគម្រោងនេះពុំបានធ្វើឱ្យប៉ះពាល់ និងខូចខាតធនធានបរិស្ថានធ្ងន់ធ្ងរនោះទេ។ ដូចនេះ តាមការប៉ាន់ប្រមាណ ការចំណាយលើការបង់ពន្ធរបស់ក្រុមហ៊ុនគឺ ស្មើនឹងប្រមាណ ២២៥.០០ដុល្លាសហរដ្ឋអាមេរិចក្នុងមួយឆ្នាំ។

### ៩.៤.២ ការវិភាគលើផលចំណេញដែលក្រុមហ៊ុននឹងទទួលបាន

#### ក. ការប៉ាន់ស្មានចំណូលពីការវិនិយោគគម្រោងរបស់ក្រុមហ៊ុន

ចំណូលពីការលក់សេវាប្រើប្រាស់អ៊ីនធឺណែតរបស់ក្រុមហ៊ុន TELCOTECH LTD នៅក្នុងប្រទេសកម្ពុជា ត្រូវបានប៉ាន់ស្មានស្មើនឹងប្រមាណ **៤,៥លានដុល្លាសហរដ្ឋអាមេរិច** ។ ការប៉ាន់ស្មានចំណូលពីការលក់នេះ គឺផ្អែកលើការប៉ាន់ស្មាននៃចំនួនអ្នកប្រើប្រាស់សេវាកម្ម អ៊ីនធឺណែតរបស់ក្រុមហ៊ុន TELCOTECH LTD ដែលអាចនឹងមានចំនួនជាមធ្យម ស្មើនឹង២.៥០០០ អ្នកប្រើប្រាស់ទូទាំងប្រទេសកម្ពុជា។ តម្លៃប្រើប្រាស់សេវាកម្មអ៊ីនធឺណែត ត្រូវបាន ប៉ាន់ស្មានស្មើនឹងប្រមាណ១៥ដុល្លាក្នុងមួយខែ។

#### ខ. ការវិភាគប្រៀបធៀបផលចំណេញ-ខាតរបស់ក្រុមហ៊ុនវិនិយោគ (Cost-Benefit Analysis)

ចំពោះគម្រោងមួយ ដែលអាចដំណើរការទៅបាន គឺត្រូវមាននិរន្តរភាពហិរញ្ញវត្ថុរបស់ខ្លួនផ្គួបផ្សំនឹងប្រសិទ្ធិភាពផ្នែកសេដ្ឋកិច្ចនៃការប្រតិបត្តិគម្រោង។ ផ្ទុយទៅវិញ ប្រសិនបើគម្រោងនោះពុំមាននិរន្តរភាពហិរញ្ញវត្ថុទេ នោះផលចំណេញផ្នែកសេដ្ឋកិច្ចនៃសង្គមជាតិ ក៏មិនអាចកើតឡើងផងដែរ។ ដូចនេះ ការវិភាគហិរញ្ញវត្ថុ (Financial analysis) និងសេដ្ឋកិច្ច (Economic analysis) ប្រៀបបាននឹងកាក់មួយមានមុខពីរ ដែលជួយបំពេញឱ្យគ្នាទៅវិញទៅមក។

បន្ទាប់ពីធ្វើការកំណត់អំពីអថេរចំណាយ និងចំណូល ដើម្បីធ្វើការវិភាគផ្នែកហិរញ្ញវត្ថុ និងការវិភាគផ្នែកសេដ្ឋកិច្ចចប់សព្វគ្រប់ហើយ យើងនឹងប្រើប្រាស់វិធីសាស្ត្រវិភាគប្រៀបធៀបផលចំណេញ-ខាត (Cost-Benefit Analysis) ដើម្បីវាស់វែង ថាតើការវិនិយោគលើគម្រោងខ្សែកាប្លិ៍អុបទិចរបស់ក្រុមហ៊ុន TELCOTECH LTD មានប្រសិទ្ធិភាពសេដ្ឋកិច្ចកម្រិតណា។ ការវិភាគប្រៀបធៀបផលចំណេញ-ខាត (Cost-Benefit Analysis) គឺជាសេដ្ឋម៉ែត្រដ៏សាមញ្ញមួយ ត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីវិភាគលើប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនៃគម្រោងអភិវឌ្ឍន៍ ហើយត្រូវបានគេប្រើប្រាស់ដើម្បីធ្វើការសម្រេចចិត្តទៅលើគម្រោងណាមួយ ដើម្បីស្វែងយល់ឱ្យច្បាស់ថាតើគម្រោងវិនិ



Draft

យោគនោះអាចប្រព្រឹត្តិទៅបាន ឬក៏យ៉ាងណាដោយផ្អែកលើផលចំណេញផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ចជាតិដែលទទួលបានពីសកម្មភាពគម្រោង។

ការប្រើប្រាស់វិធីសាស្ត្រវិភាគប្រៀបធៀបផលចំណេញ-ខាត លើគម្រោងវិនិយោគនេះ គឺដើម្បីវាស់វែងអំពីផលចំណេញសេដ្ឋកិច្ច និងកម្រិតនៃការជួយលើកកំពស់សេដ្ឋកិច្ចជាតិបានកម្រិតណា។ លើសពីនេះទៀត យើងក៏នឹងប្រើប្រាស់វិធីសាស្ត្រវិភាគរកតម្លៃនៃអត្រាចំណូលវិនិយោគខាងក្នុង (IRR) ដែលជាវិធីសាស្ត្រមួយ បង្ហាញឱ្យយើងឃើញពីអត្រានៃការទទួលបានផលចំណេញមកវិញ ដោយធៀបនឹងអត្រាការប្រាក់ ឬអត្រាអប្បហារ។

ការវិភាគផលចំណេញ-ខាត (CBA) គឺជាផលធៀបនៃផលបូកសរុបនៃតម្លៃចំណេញបច្ចុប្បន្ន (Total Present Value benefit) និងផលបូកសរុបនៃតម្លៃចំណាយបច្ចុប្បន្ន (Total Present Value cost) ដោយប្រើប្រាស់ការគណនារយៈពេល៣០ឆ្នាំ។ អត្រាការប្រាក់ ឬអត្រាអប្បហារ ត្រូវបានកំណត់យកត្រឹម១០% ដោយសារតែ អត្រាការប្រាក់ក្នុងទីផ្សារបច្ចុប្បន្នគឺប្រែប្រួលពី១០% ទៅ១៥%ក្នុងមួយឆ្នាំ ដោយអាស្រ័យទៅតាមប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍន៍។

ការគណនាតម្លៃបច្ចុប្បន្ន (Present Value) ត្រូវបានអនុលោមយកតាម អត្រាការប្រាក់ ឬអត្រាអប្បហារ (Discount rate) លើសពីអាត្រាលើទីផ្សារធនាគារពាណិជ្ជកម្មត្រឹម ១០% ក្នុងមួយឆ្នាំ ដោយ សន្មត់ថាស្ថិតក្នុងប្រភេទគណនីមានកាលកំណត់។ ការគណនាតម្លៃបច្ចុប្បន្ន (Present Value) គឺផ្អែកលើរូបមន្តដូចខាងក្រោម៖

$$PV = \frac{FV}{(1+i)^N}$$

PV=តម្លៃបច្ចុប្បន្ន FV=តម្លៃប៉ាន់ស្មាននាពេលអនាគត i=អត្រាការប្រាក់ ឬអត្រាអប្បហារ N=រយៈពេលនៃលំហូរសាច់ប្រាក់របស់គម្រោងគឺ៣០ឆ្នាំ។

សន្ទស្សន៍ផលចំណេញ (Benefit/Cost Ratio) គឺ CBA=Total PV Benefit/Total PV Cost ហើយយើងអាចទាញបានសម្មតិកម្មដូចខាងក្រោម៖

សម្មតិកម្មទី១៖ ប្រសិនបើ CBA > ១ មានន័យការវិនិយោគនេះ គឺអាចទទួលយកបាន

សម្មតិកម្មទី២៖ប្រសិនបើ CBA = 0 មានន័យការវិនិយោគនេះ គឺអាចបានរួចខ្លួនតែប៉ុណ្ណោះ

សម្មតិកម្មទី៣៖ ប្រសិនបើ CBA < ១ មានន័យថាការវិនិយោគនេះ មិនគួរបន្តដំណើរការទៀតទេ ដោយសារការចំណាយច្រើនជាងចំណូល។

តារាង៩.៣ខាងក្រោម បង្ហាញអំពីការប៉ាន់ប្រមាណនៃលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនវិនិយោគនេះដោយបានប៉ាន់ស្មានត្រឹមរយៈពេល១៥ឆ្នាំនៃការវិនិយោគ។ បន្ទាប់ពីទូទាត់ការចំណាយ

Draft

ផ្សេងៗ រួមមានការចំណាយលើដំណាក់កាលសាងសង់ និងចំណាយក្នុងដំណាក់ប្រតិបត្តិគម្រោង ក្រុមហ៊ុនអាចទទួលបាន **ផលចំណេញបច្ចុប្បន្នសុទ្ធសរុប** (NVP) ស្មើនឹងប្រមាណជិត **៦០ លានដុល្លាក្នុងរយៈពេល៣០ឆ្នាំ**។ លើសពីនេះទៀត ចំពោះលទ្ធផលនៃការវិភាគប្រៀបធៀបសន្ទស្សន៍ផលចំណេញ-ខាត (Benefit/Cost Ratio) របស់ក្រុមហ៊ុនគឺស្មើនឹង១,៥៥។ ដូចសម្មតិកម្មខាងលើបានបញ្ជាក់ថា បើតម្លៃនៃសន្ទស្សន៍ផលចំណេញ-ខាតមានតម្លៃធំជាងមួយ នោះមានន័យថាការវិនិយោគនេះនឹងមានសង្ឃឹមទទួលបានផលចំណេញខ្ពស់។ ជាឧទារណ៍ដ៏សាមញ្ញ ប្រសិនបើក្រុមហ៊ុននេះបានបោះទុនវិនិយោគ ១ដុល្លា នោះក្រុមហ៊ុននឹងទទួលចំណូលមកវិញស្មើនឹង ១,៥៥ដុល្លា ឬផលចំណេញសុទ្ធស្មើនឹង០,៥៥ដុល្លាពីការវិនិយោគក្នុង ១ដុល្លា។

លើសពីនេះទៀត ការសិក្សានេះក៏បានរកឃើញផងដែរថា តម្លៃនៃអត្រាចំណូលវិនិយោគខាងក្នុង (IRR) គឺស្មើ១២% ដែលតួលេខនេះ បង្ហាញថាក្រុមហ៊ុនមានសង្ឃឹមទទួលបានផលចំណេញច្រើន ដោយសារតែការគណនាអត្រានៃ IRR ត្រូវបានកំណត់យកអត្រាអប្បហារ (Discount rate) ត្រឹមតែ១០% ដែលជាអត្រាតូចជាងអត្រានៃ IRR។ ហើយរយៈពេលនៃការរំពឹងទទួលបានផលចំណេញពីការវិនិយោគនេះគឺត្រូវចំណាយរយៈពេលជាង៨ឆ្នាំចាប់តាំងពីឆ្នាំនៅក្នុងដំណាក់កាលសាងសង់មក។

តារាង៩.៣៖ លំហូរសាច់ប្រាក់នៃការវិនិយោគរបស់ក្រុមហ៊ុនក្នុងរយៈពេល៣០ឆ្នាំ

| Year | Future Value | | | | | Discount cash flow at 10% | | |
|---|---|---|---|---|---|---|---|---|
| | Construction Cost (USD) | Operation Cost (USD) | Total Cost (USD) | Benefit (USD) | Net Benefit (USD) | Cost (USD) | Benefit (USD) | Net Benefit (USD) |
| 1 | 9,300,000 | 40,000 | 9,340,000 | - | (9,340,000) | 9,340,000 | - | (9,340,000) |
| 2 | 11,750,000 | 40,000 | 11,790,000 | - | (11,790,000) | 11,000,459 | - | (11,000,459) |
| 3 | 300,000 | 40,000 | 340,000 | - | (340,000) | 304,626 | - | (304,626) |
| 4 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 665,971 | 3,917,478 | 3,251,506 |
| 5 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 6 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 7 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 8 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 9 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 10 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 11 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 12 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 13 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 14 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 15 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 16 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 17 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 18 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 19 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 20 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |



Draft

| Year | Future Value | | | | | Discount cash flow at 10% | | |
|---|---|---|---|---|---|---|---|---|
| | Construction Cost (USD) | Operation Cost (USD) | Total Cost (USD) | Benefit (USD) | Net Benefit (USD) | Cost (USD) | Benefit (USD) | Net Benefit (USD) |
| 21 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 22 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 23 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 24 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 25 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 26 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 27 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 28 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 29 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| 30 | - | 765,000 | 765,000 | 4,500,000 | 3,735,000 | 4,500,000 | 3,735,000 | 4,500,000 |
| Total | | | | | | 36,439,621 | 92,909,037 | 56,469,416 |
| | | | | | | **Benefit-Cost Ratio** | | **1.55** |
| | | | | | | **IRR** | | **12%** |
| | | | | | | **Payback period** | | **4.1 year** |

### គ. ការវិភាគកម្រិតប្រែប្រួល (Sensitivity Analysis) នៃអត្រាអប្បហារចំពោះការវិនិយោគ

ការវិភាគកម្រិតប្រែប្រួល (Sensitivity analysis) ត្រូវបានវិភាគឡើងក្នុងគោលបំណងស្វែងរកឥទ្ធិពលនៃអតិផរណានៃផលចំណេញ និងចំណាយរបស់ក្រុមហ៊ុន។ ការវិភាគនេះត្រូវបានអនុវត្តឡើងដោយប្រើប្រាស់សេណារីយ៉ូចំនួនបី គឺ ១). សេណារីយ៉ូល្អប្រសើរ (Best Case Scenario)៖ ជាសេណារីយ៉ូត្រូវបានសម្មត់ថាអត្រាការប្រាក់ឬអត្រាអប្បហារស្មើនឹង៥%ក្នុងមួយឆ្នាំ ២). សេណារីយ៉ូធម្មតា (Base Case Scenario)៖ ជាសេណារីយ៉ូត្រូវបានសម្មត់ថាអត្រាការប្រាក់ឬអត្រាអប្បហារស្មើនឹង១០%ក្នុងមួយឆ្នាំ និង ៣). សេណារីយ៉ូក្នុងករណីមិនល្អ (Worse Case Scenario)៖ ជាសេណារីយ៉ូត្រូវបានសម្មត់ថាអត្រាការប្រាក់ឬអត្រាអប្បហារស្មើនឹង១៥%ក្នុងមួយឆ្នាំ។

លទ្ធផលនៃការវិភាគកម្រិតប្រែប្រួលនៃអត្រាការប្រាក់ក្នុងសេដ្ឋកិច្ចទីផ្សារកម្ពុជា ដោយផ្អែកលើសេណារីយ៉ូ សំខាន់ៗចំនួនបី បានបង្ហាញយ៉ាងច្បាស់ថា សេណារីយ៉ូទាំងបីសុទ្ធតែបង្ហាញអំពីប្រសិទ្ធិភាពខ្ពស់នៃការប្រតិបត្តិគម្រោង ដែលអនុគ្រោះដល់ក្រុមហ៊ុនវិនិយោគនេះ ឱ្យទទួលបានផលចំណេញច្រើនលើការវិនិយោគលើការគម្រោងខ្សែកាប្លិ៍អុបទិចរបស់ **ក្រុមហ៊ុនតេលកូថេក**។ តារាង៩.៤ ខាងក្រោមបង្ហាញថាសេណារីយ៉ូទី១ ទី២ និងទី៣ ទទួលបាន សទ្ធស្សន៍ផលចំណេញ (Benefit-cost ratio) ស្មើនឹង ១,៣៩ ១,៥៥ និង១,៧២រៀងគ្នា។ ដោយហេតុថា សទ្ធស្សន៍ផលចំណេញ នៃការវិភាគសេណារីយ៉ូទាំងបីសុទ្ធតែមានតម្លៃធំជាងមួយ នោះតាមសម្មតិកម្មខាងលើបញ្ជាក់ថាគម្រោងវិនិយោគរបស់ក្រុមហ៊ុនទទួលបានផលចំណេញច្រើន ហើយពុំមានហានិភ័យចំពោះផ្នែកហិរញ្ញវត្ថុកើតឡើងនោះទេ។

តារាង៩.៤៖ លទ្ធផលនៃការវិភាគកម្រិតប្រែប្រួល (Sensitivity Analysis)

| សូចនាករសេដ្ឋកិច្ច | Worst Case (15%) | Base Case (10%) | Best case (5%) |
|---|---|---|---|
| សន្ទស្សន៍ចំណេញ-ខាត (BCR) | 1.39 | 1.55 | 1.72 |
| អត្រាចំណូលវិនិយោគខាងក្នុង (IRR) | 11 | 12 | 13 |
| ផលចំណេញសុទ្ធបច្ចុប្បន្ន (NPV) (US$) | 47,261,241 | 56,469,416 | 67,099,773 |

## ៩.៥ ការវិភាគផលចំណេញលើសង្គម-សេដ្ឋកិច្ចជាតិពីគម្រោងវិនិយោគ

### ៩.៥.១ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាពត៌មាន និងទំនាក់ទំនង

ការវិនិយោគលើគម្រោងខ្សែកាប្លិ៍អុបទិចបង្កប់ក្រោមបាតសមុទ្ររបស់ **ក្រុមហ៊ុនតែលខូថេក** (TELCOTECH LTD) មិនត្រឹមតែផ្តល់ផលចំណេញដល់ម្ចាស់ក្រុមហ៊ុនវិនិយោគប៉ុណ្ណោះនោះទេ ការវិនិយោគនេះ ថែមទាំងចូលរួមចំណែកក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យាពត៌មានវិទ្យា និងទូរគមនាគមន៍ជូនរដ្ឋាភិបាលកម្ពុជាទៀតផង ដែលការងារនេះគឺជាទិសដៅអទិភាពរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យពត៌មានវិទ្យា និងទំនាក់ទំនងឱ្យបានទូលំទូលាយក្នុងប្រទេស ខណៈពេលដែលសេដ្ឋកិច្ចសមាគមន៍អាស៊ានខិតជិតមកដល់។ លើសពីនេះទៀត ការបង្កើតឱ្យមានបណ្តាញខ្សែកាប្លិ៍អុបទិចបង្កប់ក្រោមបាទសមុទ្រនេះវានឹងអាចរួមចំណែកឱ្យមានការកើនឡើងនូវការវិនិយោគលើវិស័យពត៌មានវិទ្យា និងទំនាក់ទំនង (ICT) នាពេលខាងមុខទៀតផង។

### ៩.៥.២ ផលចំណេញចំពោះបរិស្ថាន-សង្គម

ក្រុមហ៊ុនតែលខូថេក នឹងបន្តឆន្ទៈចូលរួមចំណែកក្នុងការគាំទ្រ និងការការពារបរិស្ថានតាមរយៈការរួមចំណែកផ្តល់ថវិការសម្រាប់ជាមូលនិធិបរិស្ថាននិងសង្គម ដែលក្រុមហ៊ុនគ្រោងនឹងចូលរួមបដិភាគប្រមាណ **៤ម៉ឺនដុល្លាសហរដ្ឋអាមេរិច** ដែលជាផ្នែកមួយនៃការទទួលខុសត្រូវលើសង្គម និងបរិស្ថាន។ លើសពីការចូលរួមជាថវិកាសម្រាប់កិច្ចការងារបរិស្ថាននិងសង្គម ក្រុមហ៊ុនតែលខូថេក ក៏នឹងផ្តល់នូវការផ្គត់ផ្គង់សេវាអ៊ីនធឺណែតដោយឥតគិតថ្លៃដល់ គ្រឹះស្ថានសិក្សាជាច្រើនទៀត ដើម្បីជួយដល់ការសិក្សារបស់យុវជនកម្ពុជានៅក្នុងប្រទេសកម្ពុជា។ មិនត្រឹមតែប៉ុណ្ណោះ ក្រុមហ៊ុនតែលខូថេក នឹងធ្វើការសិក្សា និងពិចារណាទៅមុខទៀតអំពីលទ្ធភាពនៃការជួយអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច និងសង្គមនៅកម្ពុជាទៅតាមរូបភាព ដែលអាចធ្វើបាន និងតាមការស្នើសុំរបស់រដ្ឋាភិបាល។

ក្រៅពីទទួលបានផលចំណេញពីការផ្តល់នូវមូលនិធិបរិស្ថាននិងសង្គម និងការផ្តល់នូវការ

ប្រើប្រាស់សេវាអ៊ីនធឺណែតដោយឥតគិតថ្លៃពីក្រុមហ៊ុនវិនិយោគនេះ រដ្ឋាភិបាលកម្ពុជា ក៏ដូចជាសង្គមទាំងមូលអាចនឹងទទួលបានផលប្រយោជន៍ដូចជា៖

- ប្រជាពលរដ្ឋមួយចំនួននឹងទទួលបានការងារធ្វើពីវត្តមាននៃគម្រោងនេះទាំងនៅក្នុងដំណាក់កាលសាងសង់ និងក្នុងដំណាក់កាលប្រតិបត្តិគម្រោង
- រដ្ឋាភិបាលកម្ពុជាក៏នឹងទទួលបានចំណូលបន្ថែមពីការបង់ពន្ធរបស់ក្រុមហ៊ុនផ្ទាល់ និងអាចទទួលបានពន្ធនៃប្រាក់បៀវត្សន៍របស់បុគ្គលិកក្រុមហ៊ុនផងដែរ
- ការទទួលបាននូវភាពប្រសើរឡើងនៃធនធានបរិស្ថាននៅតំបន់មួយចំនួន និងការអភិវឌ្ឍន៍សង្គមតាមរយៈការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម រដ្ឋាភិបាលកម្ពុជាអាចប្រើប្រាស់មូលនិធិបរិស្ថាន-សង្គម ដែលទទួលបានពីម្ចាស់គម្រោងយកទៅធ្វើការអភិវឌ្ឍន៍ធនធានបរិស្ថាន និងសង្គមនៅតាមតំបន់គោលដៅរបស់រដ្ឋាភិបាល។

### ៩.៥.៣ ឥទ្ធិពលអវិជ្ជមាននៃគម្រោងលើធនធានបរិស្ថាននិងសង្គម

#### ក. ផលប៉ះពាល់អវិជ្ជមានលើធនធានធម្មជាតិនៅតាមគន្លងខ្សែកាប្លិ៍អុបទិច

តាមរយៈការសិក្សាលើផលប៉ះពាល់លើធនធានជីវសាស្ត្របានបង្ហាញថាគម្រោងខ្សែកាប្លិ៍អុបទិចពុំបានបង្កផលប៉ះពាល់ធ្ងន់ធ្ងរទៅលើធនធានជីវសាស្ត្រនោះទេ ទាំងធនធានព្រៃឈើ និងធនធានសមុទ្រ ដោយសារតែគម្រោងនេះជាប្រភេទគម្រោងបង្កប់ខ្សែកាប្លិ៍អុបទិចនៅក្រោមបាតសមុទ្រ ដែលមានប្រវែង៨៨២គីឡូម៉ែត្រក្នុងដែនសមុទ្រកម្ពុជា។ លើសពីនេះទៀត គន្លងខ្សែកាប្លិ៍អុបទិចដែលត្រូវកប់នឹងមិនធ្វើឱ្យមាន ការរំខានដល់តំបន់ផ្កាថ្មនោះទេ ព្រោះគេបង្កប់វានៅតំបន់ទឹកជ្រៅចាប់ពី២០ម៉ែត្រឡើងទៅ។ មួយវិញទៀត សកម្មភាពកប់ខ្សែកាប្លិ៍អុបទិច ពុំបានបង្កផលប៉ះពាល់ដល់ពពួកស្មៅសមុទ្រនោះទេ ដោយសារតែនៅតាមគន្លងអូសខ្សែ ពុំមានវត្តមាននៃពពួកស្មៅសមុទ្រ។

ម្យ៉ាងវិញទៀត លទ្ធផលនៃការសិក្សាអំពីធនធានក្នុងសមុទ្របានបង្ហាញថាវត្តមាននៃការសាងសង់ដោយបង្កប់ខ្សែកាប្លិ៍អុបទិច ពុំបានបង្កផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ធនធានក្នុងសមុទ្រ (marine life) នោះទេ ដោយសារតែទីតាំងនៃតំបន់គម្រោងអូសខ្សែកាប្លិ៍អុបទិចបង្កប់នៅក្រោមបាតសមុទ្រគឺជាតំបន់ដែលពុំសូវមានវត្តមាននៃពពួកសត្វក្នុងសមុទ្ររស់នៅ និងតំបន់គន្លងអូសខ្សែបង្កប់ពុំមានជម្រករបស់សត្វសមុទ្រ និងអាហាររបស់សត្វសមុទ្រជាពិសេសគឺស្មៅសមុទ្រ និងផ្កាថ្ម។ ម្យ៉ាងវិញទៀត បើទោះបីជាមានការរំខានក៏គម្រោងនេះរំខានតិចតួចប៉ុណ្ណោះក្នុងដំណាក់កាលអូសខ្សែបង្កប់ ប៉ុន្តែបន្ទាប់ពីបញ្ចប់ការបង្កប់ខ្សែកាប្លិ៍រួចរាល់មក ស្ថានភាពនៃទឹកក្នុងបាតសមុទ្រនឹងវិលត្រលប់មកសភាពដើមវិញ។ ដូចនេះ ការប៉ាន់ស្មានអំពីទំហំ និងតម្លៃនៃការខូចខាតធនធានក្នុងសមុទ្រមិនត្រូវបានសិក្សាវាយតម្លៃឡើយ ដោយសារទំហំប៉ះពាល់តិចតួចពេក ហើយវានឹងអាចវិលត្រលប់មកសភាពដើមក្រោយការបង្កប់ខ្សែកាប្លិ៍របស់គម្រោងរួច។

### ខ. ផលប៉ះពាល់អវិជ្ជមានលើធនធានសង្គមនៃការវិនិយោគគម្រោងខ្សែកាប្លិ៍អុបទិច

ទីតាំងគម្រោងដែលត្រូវអូសខ្សែកាប្លិ៍ មិនអាចជៀសផុតពីតំបន់នេសាទនោះទេ។ តែទោះជាយ៉ាងណា បន្ទាប់ពីខ្សែកាប្លិ៍ត្រូវបានបង្កប់រួច ការនេសាទនឹងអាចដំណើរការបានធម្មតា។ ផ្ទុយទៅវិញ សកម្មភាពនេសាទទៅវិញទេ ដែលអាចប៉ះពាល់នឹងខ្សែកាប្លិ៍ដែលបានបង្កប់នៅក្រោមសមុទ្រ ដោយសារយុថ្កា និងឧបករណ៍នេសាទទម្លាក់ចុះក្រោម។ ទីតាំងនេសាទត្រីទឹកសមុទ្រនៅកម្ពុជា គឺនៅក្នុងឈូងសមុទ្រថៃ ដែលមានជម្រៅក្រោម ២០ម៉ែត្រ សម្រាប់ទូកនេសាទលក្ខណៈគ្រួសារ និងចាប់ពីជម្រៅ ២០ម៉ែត្រឡើងទៅសម្រាប់ទូកនេសាទធ្វើអាជីវកម្ម។ ចំពោះការនេសាទនៅទឹករាក់ក្រោម ២០ម៉ែត្រ ដែលជាលក្ខណៈគ្រួសារ ពុំបង្កផលប៉ះពាល់លើតំបន់ខ្សែកាប្លិ៍អុបទិច ដែលកប់នោះទេ។ រីឯ ការនេសាទជាលក្ខណៈអាជីវកម្មវិញ គឺអាចមានផលប៉ះពាល់ខ្សែកាប្លិ៍ដែលបានបង្កប់ ដោយសារតែ ឧករណ៍សំណាញ់ និងអន្ទាក់បង្កង។ ដូចនេះ តាមរយៈការវិនិយោគនេះ ពុំបានបង្កផលប៉ះពាល់អវិជ្ជមានលើការប្រកបរបរនេសាទរបស់ប្រជានេសាទនោះទេ។ ចំណែកឯ ការបង្កប់ខ្សែកាប្លិ៍អុបទិចលើដីគោកប្រវែង១គីឡូម៉ែត្រនៅតាមតំបន់ឆ្នេរវិញ ក៏ពុំបានបង្កផលប៉ះពាល់ដល់ការប្រកបមុខរបររកស៊ីរបស់អាជីវករលក់ដូរនោះទេ ដោយសារតែទំហំនៃការកប់ខ្សែកាប្លិ៍អុបទិចគឺមានទំហំការងារតូច និងចំណាយពេលវេលាខ្លីក្នុងការធ្វើការងារបង្កប់លុបខ្សែកាប្លិ៍។

## ៩.៦ សេចក្តីសន្និដ្ឋាន

ការវិនិយោគរបស់ **ក្រុមហ៊ុនតែលខូថេក** លើគម្រោងខ្សែកាប្លិ៍អុបទិចបង្កប់ក្រោមបាតសមុទ្រពិតជាអាចផ្តល់នូវផលប្រយោជន៍ចំពោះក្រុមហ៊ុនវិនិយោគ និងផលប្រយោជន៍ដោយផ្ទាល់និងដោយប្រយោលដល់រដ្ឋាភិបាលកម្ពុជា។ ចំពោះផលប្រយោជន៍ចំពោះក្រុមហ៊ុន យើងសិក្សាឃើញថា ក្រុមហ៊ុនអាចនឹងទទួលបានផលចំណេញផ្នែកហិរញ្ញវត្ថុច្រើនដោយសារការវិភាគតម្លៃសេដ្ឋកិច្ចនៃការវិនិយោគឃើញថា សន្ទស្សន៍ផលចំណេញ-ខាតរបស់ការវិនិយោគនេះគឺស្មើនឹង១,៥៥ ដែលមានន័យថាបើក្រុមហ៊ុនវិនិយោគ១ដុល្លានោះក្រុមហ៊ុន នឹងទទួលបានផលចំណេញសុទ្ធមកវិញ ០,៥៥ដុល្លា ហើយរយៈពេលនៃការទទួលបានផលចំណេញមកវិញគឺចន្លោះឆ្នាំទី៤ និងទី៥។ រីឯផលចំណេញចំពោះរដ្ឋាភិបាល និងសង្គមជាតិវិញ គឺអាចទទួលបានពីគម្រោងវិនិយោគនេះដូចជាមូលនិធិបរិស្ថាន-សង្គមសម្រាប់ការអភិវឌ្ឍបរិស្ថាន និងសង្គម ការផ្តល់ការងារធ្វើដល់ប្រជាជនកម្ពុជា ការទទួលបានពន្ធនៃប្រាក់ចំណេញពីការវិនិយោគគម្រោង ការផ្តល់នូវការផ្គត់ផ្គង់ការគ្រប់ដណ្តប់សេវាអ៊ីធឺណែតទូទាំងប្រទេសសម្រាប់ភាពងាយស្រួលដល់ការវិនិយោគនៅកម្ពុជា។ លើសពីនេះទៀត ក្រុមហ៊ុននឹងចូលរួមចំណែកផ្តល់នូវសេវាប្រើប្រាស់អ៊ីធឺណែតដោយឥតគិតថ្លៃនៅតាមបណ្តាគ្រឹះស្ថានអប់រំនៅក្នុងប្រទេសកម្ពុជាទៀតផង ដើម្បីជួយលើកកម្ពស់ការអប់រំនៅកម្ពុជាឱ្យមានទំនើបកម្មកាន់តែល្អប្រសើរ។

Draft